# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 1 – Getting there
## មេរៀនទី១៖ ការធ្វើដំណើរទៅដល់គោលដៅ

**STUDY NOTES**

ឯកសារជំនួយមេរៀន

តួអង្គ

| | |
|---|---|
| Rocky: | ភ្ញៀវទេសចរប្រុសវ័យក្មេង មកប្រទេសអូស្ត្រាលីលើកទីមួយ |
| Angel: | ជានិស្សិតនារី ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។ |
| Immigration Officer: | មន្ត្រីអន្តោប្រវេសន៍នៅអាកាសយានដ្ឋានទីក្រុងមែលប៊ិន។ |

សាច់រឿង

រ៉ុកឃី ទើបតែមកដល់អាកាសយានដ្ឋានទីក្រុងមែលប៊ិន។ ខណៈពេលដែលគាត់កំពុងតម្រង់ជួររង់ចាំនៅកន្លែងអន្តោប្រវេសន៍ អែនជល ដែលជាអ្នកទើបមកដល់ថ្មីដែរនោះ ប្រាប់រ៉ុកឃីថា គាត់ឈរខុសជួរហើយ។ នៅពេលរ៉ុកឃីទៅដល់តុអន្តោប្រវេសន៍ មន្ត្រីអន្តោប្រវេសន៍ក៏ប្រាប់គាត់ឱ្យបំពេញប័ណ្ណអ្នកដំណើរ។

ព័ត៌មាន

នេះគឺជាបញ្ជីឯកសារដែលលោកអ្នកគួរយកតាមខ្លួន នៅពេលលោកអ្នកធ្វើដំណើរទៅប្រទេសអូស្ត្រាលី។ សូមទុកឯកសារច្បាប់ដើមនៅក្នុងវ៉ាលិសស្ពាយជាប់ខ្លួន និងទុកឯកសារថតចម្លងនៅក្នុងវ៉ាលិសផ្ញើតាមយន្តហោះ។

- លិខិតឆ្លងដែនដែលមានសុពលភាព និងទិដ្ឋាការសិស្សចូលប្រទេសអូស្ត្រាលីដែលមានសុពលភាព
- លិខិតបញ្ជាក់ចុះឈ្មោះចូលរៀន ឬការអនុញ្ញាតពីគ្រឹះស្ថានសិក្សាអប់រំ ដែលលោកអ្នកនឹងត្រូវទៅសិក្សា
- លិខិតបញ្ជាក់អំពីការមកទទួលដំណើរធ្វើឡើងដោយសាលាលោកអ្នក
- ព័ត៌មានពីកន្លែងស្នាក់នៅរបស់លោកអ្នក
- សំបុត្រកំណើត ប័ណ្ណឥណទានធនាគារ ប័ណ្ណបើកបរអន្តរជាតិ ប្រសិនបើមាន
- សូមយកមកជាមួយនូវលេខទូរស័ព្ទ និងអាសយដ្ឋានសំខាន់ៗនៅក្នុងប្រទេសរបស់លោកអ្នក និងប្រទេសអូស្ត្រាលី
- សូមយកមកជាមួយនូវវេជ្ជបញ្ជា និង/ឬសំបុត្របញ្ជាក់ពីវេជ្ជបណ្ឌិតសម្រាប់ការប្រើប្រាស់ថ្នាំពេទ្យ។ ប៉ុន្តែលោកអ្នកត្រូវរក្សាទុករាល់ស្លាកសញ្ញាលើដបថ្នាំទាំងអស់។


© RadioAustralia/AMES 2008

<u>ភាសាសម្រាប់ប្រើប្រាស់នៅអាកាសយានដ្ឋាន</u>

| | |
|---|---|
| Quarantine Requirements | ទាក់នឹងអ្វីដែលលោកអ្នកអាច និងមិនអាចយកចូលប្រទេសអូស្ត្រាលី |
| Customs | ក្រសួងរបស់រដ្ឋាភិបាល និងចំណុចត្រួតពិនិត្យនៅអាកាសយានដ្ឋាន ធ្វើការត្រួតពិនិត្យ ដើម្បីធានាថា លោកអ្នកមិនបាននាំមកជាមួយនូវរបស់ដែលបណ្ដាលឱ្យឆ្លងជំងឺ ឬសារធាតុខុសច្បាប់ ចូលក្នុងប្រទេសអូស្ត្រាលី។ |
| Declared goods: | ទាំងនេះគឺជាវត្ថុឬទំនិញដែលគេឃាត់ទុកដើម្បីពិនិត្យសុខភាព ដែលលោកអ្នកត្រូវគូសក្នុងប្រអប់ក្នុងទម្រង់បែបបទប្រកាសរបស់ក្រសួងគយ។ មន្ត្រីសមត្ថកិច្ចអាចដកហូត ឬមិនដកហូតទំនិញទាំងនេះ  ប៉ុន្តែ ប្រសិនបើអ្នកមិនប្រកាសប្រាប់គេទេនោះ លោកអ្នកអាចប្រឈមនឹងការផាកពិន័យយ៉ាងធ្ងន់ធ្ងរ។ |
| DIAC (The Department of Immigration and Citizenship) | ពីមុនមានឈ្មោះថា DIMA (ក្រសួងអន្តប្រវេសន៍ និងកិច្ចការពហុវប្បធម៌)។ ប៉ុន្តែនៅពេលនេះ DIAC ទទួលបន្ទុកលើការអនុញ្ញាត និងការត្រួតពិនិត្យទិដ្ឋាការ ស្ថានភាពចំណាកស្រុកឬអន្តោប្រវេសន៍ និងសញ្ជាតិ។ |
| Jetlag | ការដែលមានអារម្មណ៍វិលមុខ និងនឿយហត់ធីងធោង បន្ទាប់ពីធ្វើដំណើរតាមយន្តហោះក្នុងរយៈពេលដ៏យូរ ទៅកាន់ប្រទេសមួយដែលប្រើម៉ោងខុសគ្នាខ្លាំង។ |
| Baggage,luggage, (also bags, suitcases, cases) | ពាក្យទាំងអស់នេះ អាចប្រើជំនួសគ្នាបាន។ |
| Carry-on luggage | វ៉ាលិសអីវ៉ាន់ដែលលោកអ្នកអាចដាក់នៅក្នុងឃ្លុបយន្តហោះនៅជិតខ្លួន។ |
| Check-in luggage | វ៉ាលិសផ្ញើដាក់ក្នុងកន្លែងដាក់ទំនិញក្នុងយន្តហោះ។ |
| Baggage Carousel | កន្លែងដែលលោកអ្នកយកវ៉ាលិសផ្ញើតាមយន្តហោះ។ |


© RadioAustralia/AMES 2008

| | |
|---|---|
| Detector (sniffer) dogs | ប្រើប្រាស់ដើម្បីស្វែងរកសារធាតុខុសច្បាប់នៅក្នុងវ៉ាលិសអ្នកធ្វើដំណើរ។ ភាគច្រើន ឆ្កែទាំងនេះធ្វើសកម្មភាពនៅកន្លែងលើកអីវ៉ាន់។ ឆ្កែទាំងនេះមិនបង្កឱ្យមានគ្រោះថ្នាក់អ្វីឡើយ។ |
| Letter of Acceptance | សំបុត្រជាផ្លូវការពីមហាវិទ្យាល័យបញ្ជាក់ពីការចុះឈ្មោះចូលរៀនរបស់លោកអ្នក។ |
| International Student Pickup (Meeting Point) | ជាកន្លែងដែលមានបណ្តាញមកទទួលលោកអ្នកទៅទីក្រុង ឬទៅកន្លែងស្នាក់នៅ។ សូមកត់ចំណាំថា លោកអ្នកត្រូវតែរៀបចំ និងបង់ប្រាក់សម្រាប់សេវានេះ តាមរយៈមហាវិទ្យាល័យរបស់លោកអ្នក ឱ្យបានមុនពេលលោកអ្នកចាកចេញពីប្រទេសរបស់លោកអ្នក។ |

## EXERCISES
## លំហាត់

### ១ វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសម្លេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| Announcement | Attention | Bin |
| (to) confiscate | International | Interpreter |
| procedure | Queue | Search |
| student | Tourist | Visa |

### ២ ការហាត់រៀនភាសាៈលំហាត់គំរូ- *តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស*

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវប្រឡងដើម្បីកំណត់នូវកម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅគឺគេសរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best fits each space in the text below.


© RadioAustralia/AMES 2008

| |
|---|
| **Australia**<br>Australia is a land of contrasts. The central parts__(1)__Australia are desert and bush land. There are rainforests in the northeast and in the southeast there are snowfields. Approximately 70% of Australians live__(2)__one of the eight major cities.<br>__(3)__one in four Australians was born in another country and there are more__(4)__one hundred different ethnic groups. Approximately 17% of Australians speak a language other than English__(5) home. |

សូមគូសខ្វែងក្នុងប្រអប់នៃពាក្យនីមួយៗ។ ឧទាហរណ៍ ☒ of

| | | | |
|---|---|---|---|
| (1) | ☐ of | ☐ in | ☐ at |
| (2) | ☐ at | ☐ in | ☐ from |
| (3) | ☐ among | ☐ about | ☐ between |
| (4) | ☐ that | ☐ for | ☐ than |
| (5) | ☐ of | ☐ in | ☐ at |

## ៣ ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូរសម្លេង **/s/** ៖ សូមហាត់ពត់អណ្តាតបញ្ចេញសូរសម្លេងនេះឲ្យបានឮៗ៖

**'Stand still while we search your suitcase.'**

## ៤ អាសយដ្ឋានអ៊ីនធើណិតដែលមានប្រយោជន៍

| | |
|---|---|
| ស្ថានទូតអូស្ត្រាលី<br>ស្ថានកុងស៊ុល, ស្នងការជាន់ខ្ពស់ | http://www.dfat.gov.au/missions/ |
| ព័ត៌មានអំពីទិដ្ឋាការអូស្ត្រាលី | www.immi.gov.au |
| ឮអំពី ELICOS | www.elicos.com/about-elicos.php |
| NEAS - ជាស្ថាប័ន | www.neasaustralia.com/fst.html |


© RadioAustralia/AMES 2008

| | |
|---|---|
| ទទួលស្គាល់ សាលារៀន ELICOS | |
| ស្ថាប័ន/គ្រឹះស្ថានសិក្សាអប់រំនៅប្រទេសអូស្ត្រាលី | http://studyinaustralia.gov.au/sia/splash2.aspx |
| ការសិក្សានៅទីក្រុងមែលប៊ិន | http://www.studymelbourne.vic.gov.au/ |
| បទបង្ហាញពីសំណុំលិខិតទិដ្ឋាការ | **http://www.ausgovindia.com/ndli/files/FILE%20PRESENTATION%20for%20students%2epdf** |
| អ៊ីមែលសាកសួរព័ត៌មានពីគយនៅអូស្ត្រាលី | www.customs.gov.au<br><br>information@customs.gov.au |

ចម្លើយលំហាត់ទី២៖ 1) of 2) in 3) about 4) than 5) at

ABC Radio Australia
ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008